ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ

វាយតំលៃនិងប្រគល់កិច្ចសន្យា គបវប (PEAC)

លេខ : 105 PEAC. អក

រាជធានីភ្នំពេញ , ថ្ងៃទី 07 ខែ កុម្ភៈ ឆ្នាំ2014

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដេញថ្លៃផ្គត់ផ្គង់ Pole , Insulator & Cross arm ចំនួន 13 មុខ

## ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនផ្គត់ផ្គង់សំភារៈអគ្គិសនីក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ Pole , Insulator & Cross arm ចំនួន 13 មុខ ជូននាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្ម អាស័យដ្ឋាន ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ចាប់ពី *ថ្ងៃទី 11 ខែ កុម្ភៈ ឆ្នាំ2014* តទៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម *ថ្ងៃទី11 ខែ មីនា ឆ្នាំ2014* វេលា *ម៉ោង14:00* គត់ ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាស័យដ្ឋានខាងលើ វេលា *ម៉ោង15:30 ថ្ងៃទី 11 ខែ មីនា ឆ្នាំ 2014* ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរពិតមានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

សូមទាក់ទង

ទូរស័ព្ទលេខ : 023 67 66 007

Website : www.edc.com.kh

ចំលងជូន :

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ "
- ឯកសារ-កាលប្បវត្តិ

ELECTRICITE DU CAMBODGE